ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ២៧៦១ រថ.អកទទ.សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការកែសម្រួលសមាសភាពក្រុមអ្នកនាំពាក្យក្រសួងរ៉ែ និងថាមពល សម្រាប់ឆ្នាំ២០១៧

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ដែលបានកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤០១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្ទេរ និងធ្វើសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជា ទៅក្រោមក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរ៉ែ និងថាមពល
- បានឃើញសេចក្តីសម្រេចលេខ ០០៣ រថ.រប.សសរ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលសមាសភាពក្រុមអ្នកនាំពាក្យក្រសួងរ៉ែ និងថាមពល
- យោងតាមការចំបាច់របស់ក្រសួងរ៉ែ និងថាមពល

## សម្រេច

**ប្រការ ១_** ត្រូវបានកែសម្រួលសមាសភាពក្រុមអ្នកនាំពាក្យក្រសួងរ៉ែ និងថាមពល ដែលមានចែងក្នុងប្រការ១នៃសេចក្តីសម្រេចលេខ ០០៣ រថ.រប.សសរ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលសមាសភាពក្រុមអ្នកនាំពាក្យក្រសួងរ៉ែ និងថាមពលសម្រាប់ឆ្នាំ២០១៧ មកសមាសភាពថ្មីដូចខាងក្រោម៖

១.ឯកឧត្តម **យស មុនីរ៉ាត់** អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ

២.ឯកឧត្តម **ទិចឆ័រ ហ្សុនា** អគ្គនាយកនៃអគ្គនាយកដ្ឋានថាមពល

៣.ឯកឧត្តម **ជៀប សួរ** អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត

៤.ឯកឧត្តម **ស៊ុយ ឌីម៉ង់** អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ

**ប្រការ ២_** ក្រុមអ្នកនាំពាក្យនេះមានភារកិច្ចដូចតទៅ៖

- ទាក់ទង និងឆ្លើយឆ្លងជាផ្លូវការជាមួយសាធារណជន បណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ
- សហការជាមួយអង្គភាពចំណុះក្រសួងរ៉ែ និងថាមពល ដើម្បីប្រមូលព័ត៌មាន និងឯកសារ ដែលពាក់ព័ន្ធនឹងមូលដ្ឋានក្នុងការឆ្លើយបំភ្លឺជាមួយសាធារណជន និងសារព័ត៌មាននានា
- រាយការណ៍រាល់ការស្រាយបំភ្លឺទាំងឡាយណាក្នុងនាមក្រសួងជូនថ្នាក់ដឹកនាំ(**រដ្ឋមន្ត្រី**)
- បំពេញភារកិច្ចដទៃទៀតតាមការចាត់តាំងរបស់រដ្ឋមន្ត្រី

**ប្រការ ៣_** សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤_** សាមីខ្លួនដូចមានចែងក្នុងប្រការ១ នៃសេចក្តីសម្រេចនេះ ត្រូវអនុវត្តតាមភារកិច្ចដូចមានចែងក្នុងប្រការ២ នៃសេចក្តីសម្រេចនេះ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

ស៊ុយ សែម

**កន្លែងទទួល ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ "ដើម្បីជូនជ្រាប"

-គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងរ៉ែ និងថាមពល

-ដូចប្រការ១ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ